

# ការតភ្ជាប់អាជ្ញាធរ និង សង្គមស៊ីវិល

*"**អភិបាលកិច្ចល្អ**" គឺជាពាក្យពេញនិយមដែលត្រូវបានប្រើនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើនឆ្នាំមកហើយ និងត្រូវបានប្រើនៅក្នុងប្រទេសកម្ពុជាផងដែរ ។ នៅក្នុងផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិ ឆ្នាំ២០១៤-២០១៨ ដែលបានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា **អភិបាលកិច្ចល្អ** គឺជាយុទ្ធសាស្ត្រគន្លឹះមួយ ដោយមានផែនការសកម្មភាពមួយចំនួន ។ បច្ចុប្បន្ន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ កំពុងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់នៃស្ថាប័នរដ្ឋរួមទាំងថ្នាក់ឃុំ នៅខេត្តរតនគិរីផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាឃុំចំនួនពីរនៅក្នុងខេត្តរតនគិរី ត្រូវបានជ្រើសរើស ដើម្បីធ្វើឲ្យ**អភិបាលកិច្ចល្អ**របស់ពួកគាត់កាន់តែប្រសើរឡើងដោយមានជំនួយពីអាយស៊ីស៊ី ពួកគាត់បានស្នើសុំឲ្យក្រុមការងារអាយស៊ីស៊ីនៅខេត្តរតនគិរី រៀបចំសិក្ខាសាលាស្តីអំពី**អភិបាលកិច្ចល្អ**សម្រាប់ពួកគាត់ ។*

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមទាំងឡាយនៅថ្នាក់ឃុំក្នុងខេត្តរតនគិរី គឺក្រុមប្រឹក្សាឃុំមានបទពិសោធន៍ពីការចូលរួមរបស់អ្នកសហគមន៍នៅមានកម្រិតនៅឡើយ ជាឧទាហរណ៍នៅពេលធ្វើផែនការវិនិយោគឃុំប្រចាំឆ្នាំ។ ថ្វីបើក្រុមប្រឹក្សាឃុំ ស្វះស្វែងឲ្យការចូលរួម និងឲ្យមានការពាក់ព័ន្ធពី អ្នកសហគមន៍ដែលជាធាតុសំខាន់នៃអភិបាលកិច្ចល្អក៏ដោយ ក៏អ្នកសហគមន៍មួយចំនួនធ្វើការស្តីបន្ទោសដល់ក្រុមប្រឹក្សាឃុំ ប្រសិនបើពួកគេមិនពេញចិត្តនឹងដំណើរការ និងលទ្ធផលដែលទទួលបាន។ តាមការយល់ឃើញរបស់សហគមន៍ ពួកគេមានគិតថា ក្រុមប្រឹក្សាឃុំពុំសូវមានតម្លាភាព និងផ្តល់ព័ត៌មានដល់ពួកគេមិនមានលក្ខណៈងាយស្រួល និងពិបាកយល់។

គម្រោងអាយស៊ីស៊ី-អាយប៊ីស៊ីឌីអី(អប់រំ និងអភិវឌ្ឍសហគមន៍ផ្អែកលើអត្តសញ្ញាណ) បានទទួលសំណើពីក្រុមប្រឹក្សាឃុំចំនួនពីរ ដើម្បីរៀបផែនការ និងរៀបចំសិក្ខាសាលាស្តីពីអភិបាលកិច្ចល្អ។ អ្នកចូលរួម គឺជាសមាជិកក្រុមប្រឹក្សានៃឃុំទាំងពីរ ប្រធានភូមិ ចាស់ទុំ និងមនុស្សសំខាន់ៗមកពីភូមិចំនួន១០ ផ្សេងគ្នា។ សិក្ខាសាលាត្រូវបានធ្វើឡើងដោយផ្តោតលើការផ្សព្វផ្សាយ និងការយល់ដឹងរួមស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋនៅមូលដ្ឋាន និងវិស័យសង្គមស៊ីវិលផងដែរ។ វាជារឿងធម្មតានៅក្នុងប្រទេសកម្ពុជាដែលវិស័យសង្គមស៊ីវិលតែងតែទាមទារឲ្យស្ថាប័នរដ្ឋ ធ្វើឲ្យប្រសើរឡើង ឬពង្រឹងផ្នែកអភិបាលកិច្ចល្អ។ ទោះជាយ៉ាងណាក៏ដោយ ការពិភាក្សា និងការឆ្លុះបញ្ចាំងក្នុងអំឡុងពេលសិក្ខាសាលាផ្តោតសំខាន់ទៅលើ សារៈសំខាន់នៃវិស័យពីរ គឺកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិរួមគ្នា។ ដោយមានកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការជាវិជ្ជមាន មូលដ្ឋានគ្រឹះមួយត្រូវបានបង្កើតឡើង ដើម្បីបង្កើនការយល់ដឹង និងការគោរពគ្នាទៅវិញទៅមក។ ហេតុដូច្នេះហើយ ដោយមានការជឿទុកចិត្តកាន់តែខ្លាំងរវាងក្រុមប្រឹក្សាឃុំ និងអ្នកសហគមន៍ អភិបាលកិច្ចល្អត្រូវបានពង្រឹង។

ការរៀនសូត្រដ៏សំខាន់មួយពីសិក្ខាសាលា គឺថាអភិបាលកិច្ចល្អ ជាអ្វីមួយដែលតែងតែអាចត្រូវបានធ្វើឲ្យប្រសើរឡើង និងត្រូវបានពង្រឹង។ ដូច្នេះទាំងស្ថាប័នរដ្ឋ និងវិស័យសង្គមស៊ីវិល ចាំបាច់ត្រូវបន្តធ្វើការសម្រាប់បុព្វហេតុអភិបាលកិច្ចល្អ និងសហការជិតស្និទ្ធដោយការសន្ទនាគ្នាប្រកបដោយការគោរព។

លទ្ធផលពីសិក្ខាសាលា ក៏ជាប្រយោជន៍សម្រាប់ការងារគម្រោងអាយប៊ីស៊ីឌីអីផងដែរ តាមរយៈសិក្ខាសាលាធ្វើឲ្យទំនាក់ទំនងរវាងអ្នកចូលរួម និងក្រុមការងារអាយប៊ីស៊ីឌីអី កាន់តែជិតស្និទ្ធ។ ការណ៍នេះ នឹងផ្តល់ផលប្រយោជន៍ដល់ការអនុវត្តបន្ថែមទៀតរបស់គម្រោងអាយប៊ីស៊ីឌីអីសម្រាប់ជនជាតិដើមភាគតិច ក្នុងខេត្តរតនគិរី។

កាលបរិច្ឆេទ៖ វិច្ឆិកា ២០១៧